# វេទិកាផ្លាស់ប្តូរបទពិសោធន៍
# រវាងខេត្តគោលដៅទាំងពីរអំពីភាពជោគជ័យ និងបញ្ហាប្រឈមនៃ
# ការអនុវត្តគម្រោងលើកកម្ពស់សិទ្ធិស្ត្រីតាមរយៈការពង្រឹង
# ចំណេះដឹង និងជំនាញរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

---

## បង្ហាញដោយ ៖ លេខាធិការដ្ឋាន គ.ជ.អ.ប

## គាំទ្រមូលនិធិដោយ ៖ អង្គការ  UN Women

## ខេត្តកំពត,ថ្ងៃទី១០-១៣ ខែកុម្ភៈ ឆ្នាំ២០១៤

# ការសិក្សាវាយតម្លៃ
# អំពីការអនុវត្តគម្រោង សមិទ្ធផល និងមេរៀន
# បទពិសោធន៍

---

ដកស្រង់ខ្លឹមសារចេញពីឯកសារវាយតម្លៃអំពីអំពីការអនុវត្តគម្រោង សមិទ្ធផល និងមេរៀនបទពិសោធន៍ដែលរៀបចំដោយទីប្រឹក្សាឯករាជ្យ

លេខាធិការដ្ឋាន គ.ជ.អ.ប

# មាតិកា

១. ការចាប់ផ្តើម

២. អំពីគម្រោង

៣. ការសិក្សាអំពីវិធីសាស្រ្ត

៤. របកឃើញ

៥. សេចក្តីសន្និដ្ឋាន

៦. អនុសាសន៍

# ១. ការចាប់ផ្តើម

- លេខាធិការដ្ឋាន គ.ជ.អ.ប បានចុះហត្ថលេខាជាមួយអង្គការយូអិនវូមិន ក្នុងការអនុវត្តគម្រោងរយៈពេល១ឆ្នាំកន្លះអំពីគម្រោងលើកកម្ពស់សិទ្ធិស្ត្រី តាមរយៈការពង្រឹងចំណេះដឹង និងជំនាញដល់រដ្ឋបាលថ្នាក់ក្រោមជាតិស្តីពីការលុបបំបាត់នូវរាល់ទម្រង់រើសអើងប្រឆាំងនិងស្ត្រី (ស៊ី-ដ) ។
- នេះគឺជា ការសិក្សារបស់ទីប្រឹក្សាឯករាជ្យជាតិ អំពីសមិទ្ធផលនិងមេរៀនបទពិសោធន៍ស្តីពីការលើកកម្ពស់ចំណេះដឹង និងជំនាញអំពីសិទ្ធិស្ត្រី  និងអនុញ្ញាស៊ី-ដ របស់មន្ត្រី និងអ្នកជាប់ពាក់ព័ន្ធនានា ក៏ដូចជាការបញ្ជ្រាបគោលការណ៍នៃអនុសញ្ញាស៊ី-ដ នៅក្នុងស្ថាប័ន និងការិយាល័យនានានៅថ្នាក់ក្រោមជាតិ ។

# ២. អំពីគម្រោង

## ❖ លទ្ធផលរំពឹងទុក

- មន្ត្រីនៅតាមអនុកម្មវិធីនានា នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត  កើនឡើងការយល់ដឹងស្តីពីអនុសញ្ញាស៊ី-ដ និងអាចយកចំណេះដឹងទាំងនោះ ទៅអនុវត្តបាននៅក្នុងការបំពេញការងាររបស់ខ្លួន ។
- មន្ត្រីថ្នាក់ក្រោមជាតិយល់ដឹងកាន់តែប្រសើរឡើងអំពីការអនុវត្តអនុសញ្ញាស៊ី-ដ ការតាមដាន និងការរៀបចំរបាយការណ៍ ។
- ផ្តល់ការគាំទ្រលើចំណាយប្រតិបត្តិការទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

# ៣. វិធីសាស្ត្រនៃការសិក្សា

## ❖ ជំហានគន្លឹះនៃការសិក្សា

1) វិភាគពីស្ថានភាពដោយផ្តោតទៅលើការប្រមូលទិន្នន័យដើម្បីស្វែងយល់អំពីបរិបទរបស់គម្រោង លទ្ធផលជាគន្លឹះ មេរៀនបទពិសោធន៍ពីអ្នកអនុវត្តគម្រោង ។

- ការប្រមូលទិន្នន័យពីរបាយការណ៍ និងឯកសារដែលមានស្រាប់នៅលេខាធិការដ្ឋាន គ.ជ.អ.ប និងថ្នាក់ក្រោមជាតិ ។
- ជូនសម្ភាសន៍ដោយជ្រើសរើសមន្ត្រីពីលេខាធិការដ្ឋាន គ.ជ.អ.ប ទីប្រឹក្សាថ្នាក់ខេត្ត ថ្នាក់ស្រុកក្នុងតំបន់គោលដៅ ។

2) ទាញចេញនូវធាតុចូលពីអ្នកទទួលផលដើម្បីកំណត់ពីការអនុវត្តល្អ និងមេរៀនបទពិសោធន៍នៃការអនុវត្ត

- រៀបចំកិច្ចពិភាក្សាជាក្រុម និងជួបសម្ភាន៍ជាមួយអ្នកទទួលផលដោយផ្ទាល់ និងអ្នកទទួលផលប្រយោលដោយធានា ។
- ភាពស៊ីសង្វាក់គ្នា និងធានាភាពអនាមិក និងរក្សាការសម្ងាត់របស់អ្នកផ្តល់ចម្លើយសម្ភាសន៍ និងមានការបែងចែងរវាង បុរស និងស្ត្រី ក្នុងពេលពិភាក្សា ។

# ៤. របកគំឃើញ

## សកម្មភាពរបស់ខេត្តគោលដៅទាំងពីរ

- ផ្នាក់ខេត្ត ៖ រៀបចំសិក្ខាសាលាផ្សព្វផ្សាយចំនួន២ផ្សេងគ្នា ស្តីពីអនុសញ្ញា ស៊ី-ដ ដល់មន្ត្រីពាក់ព័ន្ធនានានៅថ្នាក់ខេត្ត រួមបញ្ចូលទាំងអង្គការសង្គមស៊ីវិលនានា។

- ថ្នាក់ស្រុក ៖ រៀបចំសិក្ខាសាលាផ្សព្វផ្សាយពីរស្តីពីអនុសញ្ញា ស៊ី-ដ និងសិក្ខាសាលាចំនួនពីរផ្សេងទៀតស្តីពីការចែករំលែកចំណេះដឹងជាមួយក្រុមប្រឹក្សាឃុំ ដែលបានរៀបចំក្នុងស្រុកនីមួយៗ។

# ៤. របកគំហើញ (ត)

- <u>**ថ្នាក់ខេត្ត**</u>៖ បានបញ្ចូល ស៊ី-ដ ក្នុងរបៀបវារៈប្រជុំរបស់ គ.ក.ស.ក កិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងក្នុងកិច្ចប្រជុំរបស់គណៈអភិបាល។
- <u>**ថ្នាក់ស្រុក**</u>៖ បានបញ្ចូល ស៊ី-ដ ក្នុងរបៀបវារៈប្រជុំរបស់ គ.ក.ស.ក កិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងក្នុងកិច្ចប្រជុំរបស់គណៈអភិបាល។
- <u>**ថ្នាក់ឃុំ**</u>៖ មន្ត្រីបង្គោល ស៊ី-ដ ថ្នាក់ស្រុកបានបញ្ចូលក្នុងកិច្ចប្រជុំរបស់ គ.ក.ន.ក តាម សំណើរបស់ក្រុមប្រឹក្សាឃុំ ឬនៅពេលចាំបាច់។

# មុនការអនុវត្តគម្រោង

- មន្ត្រីជាច្រើនយល់ដឹងអំពីថាអ្វីទៅជាយេនឌ័រ អំពើហិង្សាក្នុងគ្រួសារ និងភាពស្មើគ្នារវាងបុរស និងស្ត្រី ប៉ុន្តែពួកគាត់មិនសូវដឹងច្បាស់អំពីអ្វីទៅជាទស្សនៈទាននៃអនុសញ្ញាស៊ី-ដ ។
- បើគ្មានការបញ្ជ្រាបអនុសញ្ញា ស៊ី-ដ ទៅក្នុងរចនាសម្ព័ន្ធរបស់ស្ថាប័នទេ នោះយើងមិនទទួលបានលទ្ធផលល្អប្រសើរឡើយ បុរសៗនៅតែមិនព្រមផ្លាស់ប្តូរឥរិយាបទ និងទទួលយកវត្តមានរបស់ស្ត្រី ។
- ជាពិសេសស្ត្រី ខ្វះការពិចារណាអំពីបញ្ហាពាក់ព័ន្ធនានារបស់ខ្លួន មានចំណេះដឹងមានកម្រិតអំពី  យេនឌ័រ និងសិទ្ធិស្ត្រី ខ្វះភាពជឿជាក់លើខ្លួនឯង ចំពោះកិច្ចការមួយចំនួនដែលបានចាត់តាំងតាម  តួនាទី និងភារកិច្ចខ្លួន ។

# មុនការអនុវត្តគម្រោង (បន្ត)

• បញ្ហាអំពើហិង្សាក្នុងគ្រួសារ ត្រូវបានលើកឡើងក្នុងកិច្ចប្រជុំ គ.ក.ស.ក ។

• ខ្វះកិច្ចសហការពីមន្ត្រីប៉ូលីស ទោះបីជាមានការស្នើសុំឱ្យជួយដោះស្រាយក៏ដោយ ។

• មន្ត្រីប៉ូលីសចាត់ទុកថាអំពើហិង្សាដែលកើតឡើងគឺជាការឈ្លោះទាស់ទែងរបស់គ្រួសារ ។

# មុនការអនុវត្តគម្រោង (បន្ត)

ស្ត្រីដែលជាសមាជិកក្រុមប្រឹក្សាស្រុក បានទិទានដល់សមាជិកក្រុមប្រឹក្សាដែលជាបុរស នៅពេលដែលគាត់ស្នើសុំការគាំទ្រ....

*“ អ្នកឯងត្រូវបានគេផ្តល់សិទ្ធិជាច្រើនរួមមកហើយ ហេតុអ្វីមិនមើលលើសមត្ថភាពខ្លួនឯងជាមុនផង ។ ពេលនោះខ្ញុំមានអារម្មណ៍ថាពិបាកក្នុងចិត្ត និងចង់យំ នៅពេលដែលពួកគេមិនព្រមស្តាប់ និងទទួលយកគំនិតរបស់ខ្ញុំ ។”*

# បន្ទាប់ពីគម្រោង

- តើអ្វីដែលធ្វើឱ្យគម្រោងស្តីពីអនុសញ្ញាស៊ី-ដ មានលក្ខណៈខុសពីគម្រោងដទៃទៀតពាក់ព័ន្ធជាមួយនឹងបញ្ហាយេនឌ័រ ពីព្រោះគម្រោងនេះបានបង្រៀនពីសិទ្ធិ និងការរើសអើងលើស្ត្រីដែលមានមនុស្សជាច្រើនជឿថាជាបញ្ហាស្មុគស្មាញដែលកំពុងកើតឡើងនៅប្រទេសកម្ពុជាមិនត្រឹមតែកម្រិតសហគមន៍ តែមានការកើនឡើងទាំងកម្រិតស្ថាប័នរបស់រដ្ឋាភិបាលនាពេលបច្ចុប្បន្ន។

# បន្ទាប់ពីគម្រោង(ត)

“និយាយអំពីអនុសញ្ញា ស៊ី-ដ ខ្ញុំចូលចិត្តចំណុចការប្រឆាំងនឹងការរើសអើងលើស្ត្រីអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានធ្វើការដើម្បីលើកកម្ពស់សិទ្ធិស្ត្រី តែនិយាយត្រឹមតែយេនឌ័រនិងសមភាពរវាងបុរស និងស្ត្រី តែពួកគេមិននិយាយពីការរើសអើងឡើយ ។ នេះសុទ្ធតែជាបញ្ហារបស់ស្ត្រីពិតនាពេលបច្ចុប្បន្ន ។ ការណែនាំស្តីពីអនុសញ្ញា ស៊ី-ដ បានជួយកំនត់បញ្ហាការរើសអើងនៅកន្លែងធ្វើការរបស់ខ្ញុំ ។ មេឃុំធ្លាប់រើសអើង និងមើលងាយសមត្ថភាពរបស់ខ្ញុំដែលជាស្ត្រី តែនៅពេលដែលខ្ញុំធ្វើការបង្ហាញពីសមត្ថភាព ហើយដោយគាត់បានចូលរួមសិក្ខាសាលាស្តីពីអនុសញ្ញា ស៊ី-ដ គាត់បានបញ្ឈប់ការរើសអើងមកលើខ្ញុំ ។ នេះគឺជាមូលហេតុដែលធ្វើឱ្យខ្ញុំយល់ដឹងពីសារៈសំខាន់ពីអនុសញ្ញា ស៊ី-ដ ត្រង់ចំនុចការរើសអើង” ។

# បន្ទាប់ពីគម្រោង (ត)

អនុសញ្ញា ស៊ី-ដ បានធ្វើឱ្យសិក្ខាកាមមានគំនិតត្រិះរិះពិចារណា និងការទទួលត្រឡប់របស់សិក្ខាកាម ជាពិសេសស្ត្រី។

*"ខ្ញុំរៀនដើម្បីវិភាគបញ្ហាដែលខ្ញុំធ្លាប់បានជួប ។* ***ឧទាហរណ៍*** *ករណីរំលោភសេពសន្ថវៈដែលម្តាយចង់ដាក់ពាក្យបណ្តឹងប្តឹងនឹងឧក្រិដ្ឋជន ប៉ុន្តែមានមនុស្សមួយចំនួនបានសម្របសម្រួលនិងស្នើឱ្យគាត់មិនគួរដាក់ពាក់បណ្តឹងព្រោះអាចបណ្តាលឱ្យមានការសងសឹកបន្ទាប់ពីអ្នកដាក់ពាក្យ ។ បន្ទាប់មក ស្ត្រីដែលជាម្តាយក៏បានយល់ស្របតាម នេះដោយសារតែគាត់ខ្វះចំណេះដឹង ។ ខ្ញុំយល់ឃើញថា នេះគឺជាការរើសអើងប្រឆាំងនឹងស្ត្រី ហើយជាអ្វីដែលយើងគួរធ្វើដើម្បីជួយគាត់ឱ្យយល់ដឹងពីច្បាប់ និងការប្រើប្រាស់ច្បាប់ដើម្បីប្រឆាំងនឹងជនល្មើស"* ។

# បន្ទាប់ពីគម្រោង (ត)

គោលការណ៍នៃអនុសញ្ញា ស៊ី-ដ ប្រើប្រាស់សម្រាប់ជាមូលដ្ឋានដើម្បីកសាងទំនុកចិត្តក្នុងការពិភាក្សាវែកញែកជាមួយបុរស ឬក៏ដើម្បីទាមទារនូវសិទ្ធិរបស់ពួកគាត់ ។

*“អនុសញ្ញា ស៊ី-ដ បានជួយខ្ញុំឱ្យផ្លាស់ប្តូរឥរិយាបទការងារពីការយល់ដឹងតិចទៅការយល់ដឹងច្រើនពីបញ្ហាយេនឌ័រ ពីការភ័យខ្លាចទៅជាមានទំនុកចិត្ត ពីការនិយាយតិចទៅការនិយាយច្រើនហើយអ្វីដែលលើសពីនេះទៅទៀតនោះ ខ្ញុំមានអារម្មណ៍ថា ចំណេះដឹងរបស់ខ្ញុំមានការរីកចំរើននៅពេលដែលខ្ញុំស្រាវជ្រាវនិងអានកាន់តែច្រើនទៅលើប្រធានបទ ជាពិសេសឯកសារដែលខ្ញុំបានទទួលពីសិក្ខាសាលាស្តីពីអនុសញ្ញាស៊ី-ដ”* ។

# បន្ទាប់ពីគម្រោង(ត)

## ដំបូងឡើងខ្ញុំបានផ្លាស់ប្តូរឥរិយាបទស្វាមីរបស់ខ្ញុំ...

*“ខ្ញុំបានទុកឯកសារនៅលើធ្នើផ្ទះ ពេលខ្លះខ្ញុំយកវាមកអាន តែខ្ញុំចង់ឱ្យស្វាមីរបស់ខ្ញុំយល់ពីអនុសញ្ញានេះឱ្យបានច្បាស់ ដូច្នេះខ្ញុំសូមគាត់អានឱ្យខ្ញុំស្តាប់ ។ ខ្ញុំបានបញ្ចុះបញ្ចូលគាត់ថា លោកប្តី ខ្ញុំមានអារម្មណ៍ខ្មាស់គេណាស់ បងគួរយល់ពីភារកិច្ចរបស់ខ្ញុំ ខ្ញុំគឺជាអ្នកអប់រំអ្នកដទៃដើម្បីបញ្ឈប់អំពើហឹង្សានិងការរើសអើង ប៉ុន្តែខ្ញុំមិនអាចផ្លាស់ប្តូរស្វាមីរបស់ខ្ញុំបាន ។ បន្ទាប់មក ស្វាមីរបស់ខ្ញុំក៏បានចាប់ផ្តើមរៀនសូត្រពីអនុសញ្ញានេះ ។*

# បន្ទាប់ពីគម្រោង (ត)

- គម្រោងស្ដីពីការលើកកម្ពស់អនុសញ្ញា ស៊ី-ដ ពិតជាបានបញ្ជ្រាបយេនឌ័រក្នុង ផអព ហើយក៏មានឥទ្ធិពលដល់គណៈកម្មាធិការជ្រើសរើសបុគ្គលិក ផអពថ្នាក់ខេត្តផងដែរ

*“ នៅពេលដែលពួកគាត់សរសេរក្នុងដំណឹងជ្រើសរើសបុគ្គលិកថា ស្ត្រីត្រូវបានលើកចិត្តឱ្យក្នុងការដាក់ពាក្យ ខ្ញុំសាកល្បងសួរពួកគាត់ថា តើគាត់មានន័យដូចម្ដេច ។ ដូច្នេះ ខ្ញុំលើកទឹកចិត្តឱ្យពួកគាត់រៀបចំបញ្ជីស្រង់ឈ្មោះបេក្ខជនជាស្ត្រីច្រើនជាងបុរសដោយឱ្យពិន្ទុ២០បន្ថែមដល់បេក្ខជនដែលជាស្ត្រី ។  កាលពីពេលមុននេះ មានប្រកាសជ្រើសរើសបុគ្គលិកមួយ ប៉ុន្តែមិនមានអ្នកដាក់ពាក្យជាស្ត្រី ពួកគាត់ក៏សម្រេចចិត្តធ្វើការប្រកាសជ្រើសរើសម្ដងទៀត ។*

# បន្ទាប់ពីគម្រោង(ត)

- គម្រោងអំពីការលើកកម្ពស់ចំណេះដឹង និងជំនាញស្តីពីសិទ្ធិស្ត្រី ស៊ី-ដ ជួយខ្ញុំឱ្យទទួលបានការងារ ។

*“ តាំងពីបានចូលរួមជាមួយគម្រោងនេះ ខ្ញុំដឹងថាចំណេះដឹងរបស់ខ្ញុំអំពីបញ្ហា ស៊ី-ដ និងយេនឌ័រត្រូវបង្កើន ដែលធ្វើឱ្យខ្ញុំមានទំនុកចិត្តក្នុងការផ្សព្វផ្សាយពត៌មានទាក់ ទងទៅនឹងបញ្ហាស្ត្រីនិងយេនឌ័រជាមួយមិត្តរួមការងារនិងអ្នកដទៃ ។ ខ្ញុំអាចនិយាយ ពិភាក្សាវែកញែកអំពីបញ្ហាស្ត្រីនិងយេនឌ័រនៅអង្គប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ។ ទីប្រឹក្សាស្រុកថ្នាក់គោលបានមានប្រសាសន៍ថា យោងតាមការខិតខំប្រឹងប្រែង និងឆន្ទះរបស់ខ្ញុំក្នុងការពង្រឹងសមត្ថភាពផ្ទាល់ខ្លួន ខ្ញុំត្រូវបានលើកទឹកចិត្តដោយអភិបាលស្រុក និងត្រូវបានជ្រើសរើសជាទីប្រឹក្សាស្រុក” ។*

# ៥. សេចក្តីសន្និដ្ឋាន

- អនុសញ្ញា ស៊ី-ដ ត្រូវបានចាត់ទុកជាលិខិតបទដ្ឋានគតិយុត្តមួយដែលពន្យល់អំពីថាតើអ្វីដែលបុរស និងស្ត្រីគួរធ្វើ ឬមិនគួរធ្វើ។
- សិក្ខាកាមដែលជាស្ត្រីជាច្រើនបានលើកឡើងថា ពួកគាត់កាន់តែមានទំនុកចិត្តលើខ្លួនឯង និងមានការគាំទ្រពីមិត្តរួមការងារដែលជាបុរសជាងមុន ក្រោយពីបានចូលរួមវគ្គបណ្តុះបណ្តាល និងគម្រោង។
- ស្ត្រីមានអារម្មណ៍ថាពួកគាត់មានភាពក្លាហានដោយសារអនុសញ្ញា ស៊ី-ដ ចំណែកបុរសចាប់ផ្តើមពិចារណាលើបទដ្ឋានមានប្រៀបលើនានារបស់ខ្លួន ហើយក៏ចាប់ផ្តើមទទួលស្គាល់ពីតួនាទីរបស់ ស្ត្រីបន្តិចម្តងៗ។

# ៥. សេចក្តីសន្និដ្ឋាន (ត)

- ស្រ្តីវ័យក្មេងបានបង្ហាញនូវទំនុកចិត្តរបស់ពួកខ្លួនក្នុងវគ្គបណ្តុះបណ្តាលស្តីពីអនុសញ្ញា ស៊ី-ដ ហើយអាចបញ្ចេញនូវទេពកោសល្យផ្ទាល់របស់ពួកគេនៅចំពោះមុខមិត្តភក្តិ និងអ្នកគ្រប់គ្រង។
- ការការផ្លាស់ប្តូរឥរិបថ ទោះបីជាតិចតួច ដោយសារមានការលើកកម្ពស់ចំណេះដឹងជា លក្ខណៈបុគ្គល និងការប្តេជ្ញាចិត្តដែលទទួលបានពីសិក្ខាសាលាផ្សព្វផ្សាយ កិច្ចប្រជុំឆ្លុះបញ្ចាំង និងការអនុវត្តតាមនានាស្តីពីអនុសញ្ញា ស៊ី-ដ។

# ៥. សេចក្តីសន្និដ្ឋាន (ត)

- គ.ក.ន.ក និងគ.ក.ស.ក គឺជាយន្តការមួយដ៏សំខាន់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ បញ្ហាជាច្រើនពាក់ព័ន្ធទៅនឹងអំពើហិង្សាលើស្ត្រី ការជួញដូរស្ត្រី និងកុមារអាចទំនាក់ទំនង តាមរយៈ គ.ក.ន.ក និង គ.ក.ស.ក យ៉ាងឆាប់រហ័ស។

- អនុសញ្ញា ស៊ី-ដ បានបញ្ជ្រាបយេនឌ័រទៅក្នុងដំណើរការជ្រើសរើសបុគ្គលិកសម្រាប់មន្ត្រីកិច្ចសន្យាថ្នាក់ស្រុក និងគោលការណ៍នៅថ្នាក់ខេត្ត។

# ៥. សេចក្ដីសន្និដ្ឋាន (ត)

- កំណើននៃការវិភាជន៍មូលនិធិឃុំសម្រាប់លើកកម្ពស់សកម្មភាពទាក់ទងទៅនឹងអនុសញ្ញា ស៊ី-ដ។ ការបន្ថែមធនធានសម្រាប់ គ.ក.ន.ក គឺជាការអភិវឌ្ឍស្ថាប័ននៅថ្នាក់ឃុំដែលរួមចំណែកលើកកម្ពស់ដំណោះស្រាយបញ្ហាសង្គម។

- ទោះបីជាយ៉ាងណាក៏ដោយ ផលប៉ះពាល់របស់គម្រោងនៅតែមានកំរិតនៅឡើយ ដោយធនធានមានកំរិតរបស់ គ.ក.ន.ក និង គ.ក.ស.ក ដើម្បីរៀបចំសកម្មភាព លើកម្ពស់ចំណេះដឹងជាមួយប្រជាពលរដ្ឋ និងកង្វះការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋាន។

# ៥. សេចក្តីសន្និដ្ឋាន (ត)

- ការផ្លាស់ប្តូរឥរិយាបថតម្រូវឱ្យមានការផ្តល់នូវតម្រូវការ និងការខិតខំប្រឹងប្រែងដ៏មាំមួនពីរដ្ឋបាលខេត្តនិងស្រុក។ នេះគឺមានន័យថា ការអនុវត្តអនុសញ្ញាស៊ី-ដ នៅខេត្តគោលដៅទាំង២ និងស្រុកចំនួន៤ក្នុងរយៈពេល១ឆ្នាំកន្លះនេះ បានត្រឹមតែផ្តល់នូវចំណេះដឹងទៅឱ្យបុគ្គល ស្ថាប័ន និងថ្នាក់ដឹកនាំមួយចំនួនតែប៉ុណ្ណោះ។
- ការផ្លាស់ប្តូរនៅកំរិតស្ថាប័នត្រូវបានធ្វើឡើងតាមរយៈកិច្ចខិតខំប្រឹងប្រែងពីបុគ្គល ជាជាងការអនុវត្តតាមនីតិវិធីប្រតិបត្តិជាស្តង់ដារ (ឧ. គោលនយោបាយជ្រើសរើសបុគ្គលិកនៅ រដ្ឋបាលថ្នាក់ក្រោមជាតិ)។

# ៥. សេចក្តីសន្និដ្ឋាន (ត)

- ការផ្លាស់ប្តូរសមាសភាព គ.ក.ន.ក (និងជួនកាលជាមួយនឹងការផ្លាស់ប្តូរនៅកំរិតថ្នាក់ដឹកនាំនៃគណបក្សនយោបាយផ្ទាល់) ឬប្រធានក្រុមប្រឹក្សាឃុំ (និងស្មៀន)អាចធ្វើឱ្យ មាន ឥទ្ធិពលទៅលើការវិភាជន៍មូលនិធិប្រចាំឆ្នាំសម្រាប់សកម្មភាពផ្នែកសេវាសង្គម ផ្សេងទៀត។
- ភាពមានកម្រិតនៃយល់ដឹងថា អនុសញ្ញា ស៊ី-ដ គឺជាឯកសារច្បាប់ និងសេចក្តីណែនាំ និងជាស្ថានភាពរើសអើងយេនឌ័រ និងស្ត្រីដែលទាក់ទងនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយនិងមូលដ្ឋានក្នុងកំឡុងពេលសិក្ខាសាលាផ្សព្វផ្សាយ។

# ៦. អនុសាសន៍

- គម្រោងនេះ ឬគម្រោងស្រដៀងគ្នាពុំគួរត្រូវបានបញ្ចប់ក្នុងដំណាក់កាលនេះទេ ពោលគឺត្រូវបន្តដើម្បីលើកកម្ពស់ចំណេះដឹងរបស់អ្នកពាក់ព័ន្ធនានា និងកសាងទំនុកចិត្តលើខ្លួនឯង ភាពវៃឆ្លាត និងការជំរុញលើកទឹកចិត្តដល់ស្ត្រី
- គម្រោងលើកកម្ពស់អនុសញ្ញា ស៊ី-ដ ត្រូវចូលរួមចំណែកក្នុងកិច្ចដំណើរការអភិបាលកិច្ចល្អ នៅមូលដ្ឋាន ស្របតាមនីតិវិធីប្រតិបត្តិការជាស្តង់ដារ និងសៀវភៅណែនាំ និងសេចក្តី ណែនាំនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

# ៦. អនុសាសន៍ (ត)

- សម្រាប់គម្រោងនាពេលអនាគត គួរពិចារណាអំពីសកម្មភាពលើកកម្ពស់ចំណេះដឹង ក៏ដូច ជាការលើកកទឹកចិត្តសម្រាប់ គ.ក.ន.ក និងគ.ក.ស.ក
- គម្រោងនាពេលអនាគត គួរយកចិត្តទុកដាក់ក្នុងការគាំទ្រការពង្រឹងសមត្ថភាពនានារបស់  គ.ក.ន.ក និង គ.ក.ស.ក លើប្រធានបទជាក់លាក់ ជំនាញសម្របសម្រួល ការអនុវត្តល្អ ក្នុងវិស័យនានា ចំណាយក្នុងការរៀបចំសម្ភារៈបណ្តុះបណ្តាល និងការផ្សព្វផ្សាយនានា...    ព្រោះបច្ចុប្បន្នធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិតនៅឡើយ ពុំអាចឆ្លើយតបនឹងតម្រូវការទាំងនេះបាននៅឡើយទេ។

# ៦. អនុសាសន៍ (ត)

- គម្រោងស្រដៀងគ្នានេះអនាគត  គួរតែបង្កើនថវិកាសម្រាប់អ្នកសម្របសម្រួលថ្នាក់ស្រុកនិងថ្នាក់ខេត្ត ដើម្បីរៀបចំឧបករណ៍ ឬសម្ភារៈបណ្តុះបណ្តាលសិក្ខាសាលាផ្តែកទៅលើការយល់ដឹងរបស់ពួកគាត់ពាក់ព័ន្ធនឹងប្រធានបទនានាដែលឆ្លុះបញ្ចាំងទៅនឹងស្ថានភាពជាក់ស្តែងនៅតាមមូលដ្ឋាន។

- គម្រោងនាពេលអនាគត ត្រូវយកចិត្តទុកដាក់អំពីការគាំទ្រប្រាក់ឧបត្ថម្ភសម្រាប់ថ្លៃ ធ្វើដំណើររបស់ឃុំឆ្ងាយៗដើម្បីចូលរួមក្នុងកិច្ចប្រជុំ និងសិក្ខាសាលានានាដែលរៀបចំ ដោយថ្នាក់ខេត្ត និងថ្នាក់ស្រុក។

# សូមអរគុណ!